ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកំណត់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋក្នុងដែនដីតំបន់ទ្រនាប់នៃដែនព្រៃលិចទឹក (តំបន់២) ជុំវិញបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២២/១២៣៦ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ដីតំបន់ទ្រនាប់នៃដែនព្រៃលិចទឹក (តំបន់២) ជុំវិញបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។

រដ្ឋបាលខេត្ត និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត មានភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវលើការគ្រប់គ្រង ថែរក្សា និងត្រូវចាត់វិធានការតាមច្បាប់ជាបន្ទាន់ ក្នុងករណីពិនិត្យឃើញថា មានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ដែនតំបន់ ២ ក្នុងភូមិសាស្ត្រខេត្តនីមួយៗរៀងៗខ្លួន។

**មាត្រា២.-**

ការចូលទន្ទ្រានកាប់កាប់ដីនិងការកាប់បំផ្លាញព្រៃលិចទឹកនៅក្នុងតំបន់២ ត្រូវបានហាមឃាត់។

រាល់ការសាងសង់ថ្មីនូវទំនប់ប្រឡាយដោយសហគមន៍ឬដោយអាជ្ញាធរមូលដ្ឋាន ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។

## ជំពូកទី២
## សិទ្ធិប្រើប្រាស់ និងអាស្រ័យផលដីក្នុងតំបន់ ២

**មាត្រា៣ .-**

រដ្ឋអាចផ្តល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលដីក្នុងតំបន់២ ជូនប្រជាពលរដ្ឋដែលបានធ្វើស្រែ ចម្ការ និងបង្កបង្កើនផលជាយូរយារមកហើយ។

**មាត្រា៤ .-**

សិទ្ធិប្រើប្រាស់ និងអាស្រ័យផល សំដៅដល់សិទ្ធិធ្វើស្រែ ចម្ការ និងបង្កបង្កើនផលជាលក្ខណៈគ្រួសារ ឬសហគមន៍ លើដីរដ្ឋក្នុងតំបន់ ២។

សិទ្ធិប្រើប្រាស់ និងអាស្រ័យផល មិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ប្រទានកម្ម អច្ច័យទាន ប្រាតិភោគ ការរឹបអូស និងការរឹបអូសជាបណ្តោះអាសន្នឡើយ។

សិទ្ធិប្រើប្រាស់ និងអាស្រ័យផលដីក្នុងតំបន់ ២ អាចត្រូវបានផ្ទេរបន្តតាមរយៈសន្តតិកម្ម ដោយម្ចាស់សិទ្ធិត្រូវស្នើសុំទៅរដ្ឋបាលសុរិយោដី ដើម្បីធ្វើបច្ចុប្បន្នភាពអំពីម្ចាស់សិទ្ធិ។

**មាត្រា៥ .-**

រដ្ឋបាលសុរិយោដីមានសមត្ថកិច្ច ធ្វើការចុះបញ្ជីនិងផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋក្នុងតំបន់២ តាមលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជី និងការផ្តល់ បណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផល

**មាត្រា៦ ._**

ការចុះបញ្ជី និងការផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋក្នុងតំបន់ ២ អាចធ្វើទៅបានក្រោយពីមានការសម្រេចផ្តល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីរដ្ឋលើសំណើរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គំរូបណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផល ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ ._**

បែបបទ និងនីតិវិធីនៃការចុះបញ្ជី និងការផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋក្នុងតំបន់២ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរទន្លេសាប និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៧កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ